ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៩ សរណន

# សារាចរណែនាំ
# ស្ដីពី
# ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

## I. បរិការណ៍នៃការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

១- ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ទោះបីជាកម្ពុជាបានជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដូចជាបច្ច័យពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិនិងការធ្លាក់ចុះសេដ្ឋកិច្ចសកល សង្គ្រាមនៅព្រំដែនបង្កឡើងដោយការឈ្លានពានពីកងទ័ពថៃ គ្រោះទឹកជំនន់ រាជរដ្ឋាភិបាលកម្ពុជាបានគ្រប់គ្រងប្រទេសដោយជំនះបានលើឧបសគ្គទាំងនោះប្រកបដោយជោគជ័យ គឺការពារបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ និងរក្សាបាននូវលំនឹងនិងប្រក្រតីភាពនៃជីវភាពរស់នៅរបស់ប្រជាជន។ លើសពីនេះទៀត កម្ពុជាត្រូវបានចាត់ទុកជាប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿននៅអាស៊ី ហើយក៏ជាប្រទេសមួយក្នុងចំណោម ៥ប្រទេស ដែលកំពុងធ្វើដំណើរឆ្ពោះទៅសម្រេចបានតាមគោលដៅសហស្សវត្សរ៍ក្នុងឆ្នាំ២០១៥ ខាងមុខ។

២- ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្របដែលបានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាអាចទប់ទល់បាននឹងវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះសេដ្ឋកិច្ចសកល ហើយឈានទៅរក្សាកំណើនប្រកបដោយស្ថិរភាព។ ជាក់ស្ដែង ក្នុងឆ្នាំ២០០៩ ជាឆ្នាំដែលកម្ពុជាបានទទួលផលប៉ះពាល់ពីវិបត្តិនេះក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវកំណើនវិជ្ជមានគឺ០,១% ក្នុងឆ្នាំ២០១០ មានកំណើន៦% ក្នុងឆ្នាំ២០១១ មានកំណើន៧,១% ក្នុងឆ្នាំ២០១២ មានកំណើន ៧,៣% ហើយត្រូវបានព្យាករណ៍ថានឹងមានកំណើនប្រមាណ៧% ក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤។ ការព្យាករកំណើនសេដ្ឋកិច្ច៧% ក្នុងឆ្នាំ២០១៤ គឺបានមកពីវិស័យកសិកម្មនឹងបន្តរក្សាកំណើនក្នុងរង្វង់៣,៨% វិស័យឧស្សាហកម្មអាចនឹងមានកំណើន១០% និងវិស័យសេវាកម្មអាចនឹងមានកំណើនប្រមាណ៦,៨%។

៣- ការសម្រេចបាននូវស្ថិរភាពកំណើនសេដ្ឋកិច្ចនេះពិតជាបានរួមចំណែកធ្វើឲ្យការអនុវត្តថវិកាសម្រេចបានលទ្ធផលល្អប្រសើរប្រាកដមែន ជាក់ស្ដែងចំណូលក្នុងស្រុកថវិកាជាតិឆ្នាំ២០១១ សម្រេច

បានកំណើន៨,៣% ស្មើនឹង១២,៨៥% នៃផ.ស.ស. និងឆ្នាំ២០១២ សម្រេចបានកំណើន២២,៨% ស្មើនឹង១៤,៥១% នៃផ.ស.ស.។ តាមការព្យាករចំណូលក្នុងស្រុកថវិការដ្ឋឆ្នាំ២០១៣នេះ នឹងសម្រេចបានកំណើន១១,៥% ស្មើនឹង១៤,៦៩% នៃផ.ស.ស.។ ដូច្នេះ បើគិតពីឆ្នាំ២០១១-២០១៣ ចំណូលក្នុងស្រុកថវិការដ្ឋបានកើនឡើងក្នុងមធ្យមភាគប្រមាណ១៤% ក្នុងមួយឆ្នាំ ធៀបនឹងការអនុវត្តចំណូលប្រចាំឆ្នាំ និងបានកើនឡើងក្នុងមធ្យមភាគប្រមាណ០,៦% នៃផ.ស.ស. ក្នុងមួយឆ្នាំ។

៤- ទន្ទឹមនឹងការអនុវត្តនយោបាយហិរញ្ញវត្ថុសាធារណៈតាមរយៈការធ្វើវិត្តកម្មចំណាយដើម្បីរួមចំណែកក្នុងការជំរុញស្ថិរភាពកំណើនសេដ្ឋកិច្ច ទប់ទល់នឹងបញ្ហាព្រំដែន អតិផរណាខ្ពស់ និងទឹកជំនន់ ចំណាយសរុបថវិការដ្ឋក្នុងឆ្នាំ២០១១ បានកើនឡើងខ្ពស់រហូតដល់២១,០២% នៃផ.ស.ស. ហើយបានធ្លាក់ចុះមកវិញនៅត្រឹម២០,៥៥% នៃផ.ស.ស. ក្នុងឆ្នាំ២០១២ និងតាមការព្យាករចំណាយសរុបថវិការដ្ឋក្នុងឆ្នាំ២០១៣ នឹងស្ថិតនៅត្រឹម២០,២៤% នៃផ.ស.ស.។ ឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយពី-៨,១៦% នៃផ.ស.ស. ក្នុងឆ្នាំ២០១១ មកនៅត្រឹម-៦,០៣% ក្នុងឆ្នាំ២០១២ និងតាមការព្យាករឱនភាពថវិកាសរុបនឹងស្ថិតនៅត្រឹម-៥,៥៥% នៃផ.ស.ស. ក្នុងឆ្នាំ២០១៣។ សម្រាប់ឆ្នាំ២០១៤ រាជរដ្ឋាភិបាលមានគោលដៅនឹងរក្សាឱនភាពថវិកាសរុបឲ្យស្ថិតនៅក្នុងរង្វង់-៥% នៃផ.ស.ស. ហើយដើម្បីសម្រេចបានតាមគោលដៅនេះ ចំណូលក្នុងស្រុកថវិការដ្ឋឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបាន១៥,២៣% នៃផ.ស.ស. និងចំណាយសរុបថវិការដ្ឋឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣% នៃផ.ស.ស.។

៥- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ គឺស្ថិតក្នុងបរិការណ៍ដែលសេដ្ឋកិច្ចតំបន់ និងពិភពលោកស្ថិតក្នុងស្ថានភាពមានកំណើនខ្ពស់ជាងមុនតែហានិភ័យនៅតែបន្តមាន ដូចជាបញ្ហាឱនភាពសេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចជប៉ុន និងកំណើនសេដ្ឋកិច្ចយឺតរបស់សហរដ្ឋអាមេរិក គួបផ្សំនឹងបរិការណ៍នយោបាយអន្តរជាតិធំៗ ដូចជាស្ថានភាពតានតឹងនៅឧបទ្វីបកូរ៉េ ភាពតានតឹងនៅសមុទ្រចិន និងភាពតានតឹងនៃកម្មវិធីនុយក្លេអ៊ែរប្រទេសអ៊ីរ៉ង់ ដែលកត្តាទាំងនេះនឹងបង្កជាបច្ច័យអវិជ្ជមានដែលមិនអាចទស្សន៍ទាយបានដល់សេដ្ឋកិច្ចសកល និងសេដ្ឋកិច្ចកម្ពុជា។ ទន្ទឹមនឹងនេះ បញ្ហាអតិផរណាដោយសារការឡើងថ្លៃប្រេង ការឡើងថ្លៃទំនិញនាំចូល និងការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្ម ក៏នៅតែជាបញ្ហាប្រឈមសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ផងដែរ។

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៤

### *ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៦- តាមការគណនារបស់វិទ្យាស្ថានជាតិស្ថិតិបង្ហាញថា កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១២ អាចសម្រេចបាន៧,៣% ក្នុងនោះ វិស័យកសិកម្មអាចសម្រេចបានកំណើន៤,៣% វិស័យឧស្សាហកម្មអាចសម្រេចបានកំណើន៩,២% និងវិស័យសេវាកម្មអាចសម្រេចបានកំណើន៨,១%។ តាមការព្យាករដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៣នេះ អាចនឹងបន្តសម្រេចបាន៧% ដូចដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង

ឆ្នាំ២០១៣។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៤,៤% ដោយសារការបន្ត កើនឡើងនៃដំណាំស្រូវ ដំឡូងមី កៅស៊ូ និងអំពៅ។ វិស័យឧស្សាហកម្មនឹងមានកំណើន១០% ដោយ សារការបន្តកើនឡើងនៃផ្នែកវាយនភណ្ឌ ការរីកចម្រើនវិស័យឧស្សាហកម្មធុនស្រាល និងផលិតផល នៃច្រវាក់ផ្គត់ផ្គង់សាកល។ វិស័យសេវាកម្មនឹងមានកំណើន៦,៥% ដែលកំណើននេះបានមកពីកំណើន វិស័យដឹកជញ្ជូននិងទូរគមនាគមន៍ វិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ និងវិស័យសេវាបម្រើម្ចាស់ អចលនទ្រព្យ។

៧- កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ តាមការព្យាករណ៍អាចនឹងបន្តសម្រេចបានក្នុងរង្វង់ ៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ ៣,៨% ដោយសារការកើនឡើងនៃ កសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងតម្រូវការទីផ្សារអន្តរជាតិ មានដូចជា ស្រូវ ពោត ដំឡូងមី កៅស៊ូ និងអំពៅ ជាដើម។ វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ១០% ដោយរំពឹងថាវិស័យ វាយនភណ្ឌនឹងអាចកើនឡើងប្រមាណ៩,៥% ដោយសារការនាំចេញទៅសហគមន៍អឺរ៉ុបនៅបន្តមិន យកពន្ធក្រោមកម្មវិធី "ទំនិញគ្រប់មុខ លើកលែងតែសព្វាវុធ" និងសក្តានុពលដែលអាចពង្រីក ផលិតកម្មនិងទីផ្សារនៃវិស័យនេះ។ ម្យ៉ាងទៀត គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការ នាំចេញអង្ករក៏បានជំរុញឲ្យមានការកើនឡើងខ្ពស់ខាងវិស័យកែច្នៃម្ហូបអាហារ និងវិស័យដែលទាក់ទង មួយចំនួនទៀត ដែលបានបង្កើនតម្លៃបន្ថែមលើផលិតផលដែលមានស្រាប់។ លើសពីនេះ គម្រោង វិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី ទាំងអគ្គិសនីប្រើប្រាស់ធ្យូងថ្មនឹងត្រូវបានដាក់ឲ្យ ដំណើរការជាបន្តបន្ទាប់ និងឧស្សាហកម្មធុនស្រាលដទៃទៀតក៏បង្កើនសកម្មភាពកាន់តែខ្លាំងក្លាដែរ។ វិស័យសេវាកម្មអាចនឹងសម្រេចបានកំណើនប្រមាណ៦,៨% ដោយសារការកើនឡើងនៃវិស័យទេសចរណ៍ វិស័យដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ និងវិស័យសេវាបម្រើម្ចាស់អចលនទ្រព្យ។ សកម្មភាពសេដ្ឋកិច្ចទូទៅ ដែលជួយជំរុញកំណើនសេដ្ឋកិច្ចនឹងបន្តកើនឡើងក្នុងល្បឿនលឿន ដោយសារការអនុវត្តគោលនយោ បាយហិរញ្ញវត្ថុ និងគោលនយោបាយស្ថិរភាពរូបិយវត្ថុ ដូចជាគោលនយោបាយជំរុញហិរញ្ញប្បទានក្នុង ក្របខ័ណ្ឌគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងគោលនយោបាយ សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យឧស្សាហកម្ម។ វិស័យអចលនទ្រព្យនិងសំណង់នឹងបន្តកើន ឡើងដោយសារតម្រូវការមានការកើនឡើង តាមរយៈលំហូរទុនចូលពីវិនិយោគបរទេស និងកំណើន សេដ្ឋកិច្ចខ្ពស់។

៨- អតិផរណានៅឆ្នាំ២០១២ មាន២,៩% ការសម្រេចបានអតិផរណាកម្រិតទាបនេះដោយសារ មានការគ្រប់គ្រងប្រុងប្រយ័ត្នបំផុតទៅលើគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈក្នុងការ បង្កើនសកម្មភាពសេដ្ឋកិច្ច-សង្គមកិច្ច ទោះបីជាអតិផរណានៅក្នុងតំបន់ និងពិភពលោកមានកម្រិតខ្ពស់ ហើយប្រាក់ដុល្លារគ្មានស្ថិរភាពក៏ដោយ។ តាមការប៉ាន់ស្មាន អតិផរណានៅឆ្នាំ២០១៣ នឹងមានកម្រិត ៤% គឺដូចគ្នាទៅនឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដោយសារ តម្រូវការចំណាយនៅក្នុងឆ្នាំ២០១៣ នឹងមានកំណើនខ្ពស់ ទាំងផ្នែកសាធារណៈនិងផ្នែកឯកជន រួម ទាំងការចំណាយសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភានីតិកាលទី៥ ជាដើម។

តាមការព្យាករ អតិផរណាប្រចាំឆ្នាំ២០១៤ នឹងមានកម្រិត៣,៥% ដោយសារមានស្ថិរភាពថ្លៃម្ហូបអាហារ និងស្ថិរភាពហិរញ្ញវត្ថុ។

៩- អត្រាប្តូរប្រាក់នៅឆ្នាំ២០១២ មានតម្លៃជាមធ្យម៤ ០៣៤រៀល ក្នុង១ដុល្លារអាមេរិក។ តាមការប៉ាន់ស្មាន អត្រាប្តូរប្រាក់នៅឆ្នាំ២០១៣ នឹងមានតម្លៃជាមធ្យម៤ ០០០រៀល ក្នុង១ដុល្លារអាមេរិក គឺដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ប៉ុន្តែទាបជាងធៀបនឹងការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលមានតម្លៃ ៤ ០៥០រៀលក្នុង១ដុល្លារអាមេរិក។ ការឡើងថ្លៃប្រាក់រៀលគឺដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងការជឿទុកចិត្តពីសាធារណជន និងជាពិសេស គោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈនិងគោលនយោបាយរូបិយវត្ថុសមស្រប។ តាមការព្យាករ នៅឆ្នាំ២០១៤ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ៤ ០០០រៀល ក្នុង១ដុល្លារអាមេរិក ដែលកម្មវត្ថុចម្បងគឺដើម្បីរក្សាគុណភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកប្រាក់រៀល។

១០- ឱនភាពគណនីចរន្តបានកើនឡើងវិញគឺពី-៣,៧៨% នៃផ.ស.ស. នៅឆ្នាំ២០១១ មក -៦,៦៣% នៃផ.ស.ស. នៅឆ្នាំ២០១២ ដោយសារការកើនឡើងការនាំចូលវត្ថុធាតុដើម និងឧបករណ៍បរិក្ខារផលិតកម្មនៃវិនិយោគផ្ទាល់ពីបរទេស។ តាមការព្យាករ ឱនភាពគណនីចរន្តនឹងធ្លាក់ចុះបន្តិចមកវិញនៅត្រឹម-៦,៤២% នៃផ.ស.ស. នៅឆ្នាំ២០១៣ និង-៦,៣៥% នៃផ.ស.ស. នៅឆ្នាំ២០១៤។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឲ្យការនាំចូលជាបណ្តើរៗ។ ទុនបម្រុងអន្តរជាតិនៅឆ្នាំ២០១២ មានចំនួន៣ ២៦៥លានដុល្លារអាមេរិក ឬប្រមាណ៤,៩ខែ នៃការនាំចូលទំនិញនិងសេវាប្រើប្រាស់ក្នុងស្រុក។ ទុនបម្រុងអន្តរជាតិនៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ អាចកើនឡើងលើសពី៤ពាន់លានដុល្លារអាមេរិក ដែលអាចធានាបានប្រមាណជាង ៤,៥ខែ នៃការនាំចូលទំនិញនិងសេវាប្រើប្រាស់ក្នុងស្រុក។

១១- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ មានគោលបំណងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពតម្លៃ ការបង្កើនការងារធ្វើ និងចិរភាពបំណុល។ ដើម្បីសម្រេចបាននូវគោលដៅរយៈពេលមធ្យមនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ពោលគឺបន្តខិតខំដើម្បី (១)សម្រេចបាននូវអត្រាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៧% (២)រក្សាអត្រាអតិផរណាឲ្យស្ថិតនៅក្រោម៥% (៣)កំណត់បំណុលបរទេសឲ្យមានកម្រិតប្រហាក់ប្រហែលនឹងលំហូរនៃហិរញ្ញប្បទាននិងការវិនិយោគផ្ទាល់ពីបរទេស និង(៤)រក្សាទុនបម្រុងអន្តរជាតិឲ្យស្មើនឹងការនាំចូលចំនួនបីខែ។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅនៃកំណើន ផ.ស.ស.ពិតឲ្យសម្រេចបានក្នុងរង្វង់៧% នៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ និងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឲ្យស្ថិតក្នុងរង្វង់៤% ក្នុងឆ្នាំ២០១៣ និង៣,៥% ក្នុងឆ្នាំ២០១៤។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធានារក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលឲ្យស្ថិតនៅក្នុងរង្វង់៤ ០០០រៀលក្នុង១ដុល្លារអាមេរិក ដោយខិតខំជំរុញបដិដុល្លារូបិយកម្មសេដ្ឋកិច្ចនៅចំពោះមុខ និងរយៈពេលវែងតាមរយៈការលើក

កម្ពស់គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។ លើសពីនេះ សម្រាប់រយៈពេលមធ្យមខាងមុខ(២០១៤-២០១៦) រាជរដ្ឋាភិបាលមានគោលដៅរក្សាកំណើនប្រចាំឆ្នាំឲ្យបានក្នុងរង្វង់៧% អត្រាអតិផរណាក្នុងរង្វង់៤% និងអត្រាប្តូរប្រាក់រៀលក្នុងរង្វង់៤ ០០០រៀល ក្នុង១ដុល្លារអាមេរិក។

*ខ- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកា*

១២- គោលនយោបាយហិរញ្ញវត្ថុសាធារណៈមានគោលដៅសំខាន់ៗដូចតទៅ ៖

• ជានាបន្តអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល *ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន* ដោយធានាបានទាំងស្រុងនូវការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យដែលផ្តល់អាទិភាពទៅលើ៖

- បន្តលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈការប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

- បន្តបង្កើនការលើកស្ទួយវិស័យកសិកម្មតាមរយៈការលើកកម្ពស់ផលិតភាពនិងពិពិធកាវូបនីយកម្មកសិកម្ម កំណែទម្រង់ដីធ្លីនិងការបោសសម្អាតមីន កំណែទម្រង់ផលផល និងកំណែទម្រង់ព្រៃឈើ។

- បន្តបង្កើនការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមរយៈការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ ការអភិវឌ្ឍវិស័យថាមពលនិងបណ្តាញអគ្គិសនី និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។

- បន្តអភិវឌ្ឍផ្នែកឯកជននិងការងារតាមរយៈការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករនិងនិយោជិក ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម។

- បន្តកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ ការលើកកម្ពស់សេវាសុខាភិបាល ការអនុវត្តគោលនយោបាយយេនឌ័រ និងការអនុវត្តគោលនយោបាយប្រជាជន។

• ធានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព។

• ធានាបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៤-២០១៦។

• ធានាបន្តអនុវត្តកម្មវិធីកែទម្រង់ កម្មវិធីអភិវឌ្ឍន៍គ្រប់ការដ្ឋាន និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។

• ធានាបន្តអនុវត្តគោលនយោយបាយចាស់សកម្មភាពថ្មីនៃវិស័យដីធ្លី ពិសេសការវាស់វែងនិងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ និងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ។

• ជានាបង្កើនចំណាយវិនិយោគក្នុងស្រុកដោយខិតខំសន្សំពីអតិរេកថវិកាចរន្ត ដើម្បីកាត់បន្ថយជាបណ្តើរៗនូវចំណាយវិនិយោគសាធារណៈដែលផ្តល់ហិរញ្ញប្បទានពីក្រៅប្រទេស ក្នុងគោលដៅរក្សាឱនភាពថវិកាសរុបឲ្យស្ថិតនៅក្នុងរង្វង់-៥% នៃផ.ស.ស.។

• ជានាបន្តការពារឲ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ។

• ពង្រឹង និងបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ដែលបានប្រើប្រាស់ក្នុងអំឡុងពេលមានវិបត្តិកន្លងមក។

• ជានាផ្តល់ការឆ្លើយតបដោយទាន់ពេលវេលា និងដោយប្រសិទ្ធភាពចំពោះវិបត្តិ និងឧបទ្ទវហេតុផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ដូចជាគ្រោះធម្មជាតិជាដើម។

១៣- ដើម្បីសម្រេចបានតាមគោលដៅខាងលើ គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៤-២០១៦ មានគោលដៅបង្កើនការប្រមូលចំណូលឲ្យមានកំណើនប្រមាណ០,៥% នៃផ.ស.ស. ក្នុងមួយឆ្នាំ ហើយពង្រឹងវិន័យ និងបង្កើនគុណភាពចំណាយដោយបន្តរឹតត្បិតចំណាយចរន្តតាមរយៈការធ្វើវិចារណកម្ម និងការធ្វើអាទិភាវូបនីយកម្មចំណាយជាមួយនឹងការបង្កើនចំណាយវិនិយោគក្នុងគោលដៅរក្សាអតិរេកថវិកាចរន្តឲ្យបានក្នុងរង្វង់៣% នៃផ.ស.ស. និងឱនភាពថវិកាសរុបឲ្យស្ថិតក្រោម-៥% នៃផ.ស.ស.ក្នុងមួយឆ្នាំ។ ដើម្បីសម្រេចគោលដៅនេះ ថវិកាឆ្នាំ២០១៣ និងឆ្នាំ២០១៤ ត្រូវបានកំណត់ដូចខាងក្រោម៖

• ចំណូលក្នុងស្រុកថវិការដ្ឋនៅឆ្នាំ២០១៣ ត្រូវសម្រេចឲ្យបាន១៤,៦៩% នៃផ.ស.ស. (ថ្នាក់ជាតិ១៣,៩៩% និងថ្នាក់ក្រោមជាតិ០,៧០%) ក្នុងនោះចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឲ្យបាន១៤,៥៦% នៃផ.ស.ស. និងចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឲ្យបាន០,១៣% នៃផ.ស.ស.។ ចំណូលចរន្តថវិការដ្ឋដែលត្រូវសម្រេចឲ្យបាន១៤,៥៦% នៃផ.ស.ស. គឺចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវសម្រេចឲ្យបាន៦,៥២% នៃផ.ស.ស. ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៥៦% នៃផ.ស.ស. (ថ្នាក់ជាតិ៤,៩០% និងថ្នាក់ក្រោមជាតិ០,៦៦%) ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវសម្រេចឲ្យបាន០,៣៦% នៃផ.ស.ស. និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១៣% នៃផ.ស.ស.។ ចំណូលក្នុងស្រុកថវិការដ្ឋឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបាន១៥,២៣% នៃផ.ស.ស. (ថ្នាក់ជាតិ១៤,២៤% និងថ្នាក់ក្រោមជាតិ០,៩៩%) ក្នុងនោះចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឲ្យបាន១៥,០៦% នៃផ.ស.ស. និងចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឲ្យបាន០,១៧% នៃផ.ស.ស.។ ចំណូលចរន្តថវិការដ្ឋដែលត្រូវសម្រេចឲ្យបាន១៥,០៦% នៃផ.ស.ស. គឺចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវសម្រេចឲ្យបាន៦,៧០% នៃផ.ស.ស. ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៩០% នៃផ.ស.ស. (ថ្នាក់ជាតិ៤,៩៦% និងថ្នាក់ក្រោមជាតិ០,៩៤%) ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវសម្រេចឲ្យបាន០,៣១% នៃផ.ស.ស. និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១៤% នៃផ.ស.ស.។

• ចំណាយសរុបថវិការដ្ឋត្រូវរក្សាឲ្យនៅត្រឹម២០,២៤% នៃផ.ស.ស.(ថ្នាក់ជាតិ១៩,៥៥% និងថ្នាក់ក្រោមជាតិ០,៩០%) នៅឆ្នាំ២០១៣ ដោយចំណាយចរន្តថវិការដ្ឋត្រូវរក្សាឲ្យបានត្រឹម

១២,២២% នៃផ.ស.ស.(ថ្នាក់ជាតិ១១,៧២% និងថ្នាក់ក្រោមជាតិ០,៧១%) និងចំណាយមូលធនត្រឹម៨,០២% នៃផ.ស.ស.។ ចំណាយសរុបថវិកាជាតិឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣% នៃផ.ស.ស. (ថ្នាក់ជាតិ១៩,៣៣% និងថ្នាក់ក្រោមជាតិ០,៩៩%) ដោយចំណាយចរន្តថវិកាជាតិនឹងកម្រិតត្រឹម១២,០៦% នៃផ.ស.ស.(ថ្នាក់ជាតិ១១,៤៧% និងថ្នាក់ក្រោមជាតិ០,៧៨%) ដោយក្នុងនោះរាជរដ្ឋាភិបាលកំពុងរៀបចំកែលម្អប្រព័ន្ធបៀវត្ស និងរៀបចំគោលនយោបាយដំឡើងប្រាក់បៀវត្សដោយផ្អែកលើកំណើនសេដ្ឋកិច្ច អតិផរណា និងលទ្ធភាពថវិកា ក្នុងទិសដៅលើកកម្ពស់ផលិតភាពការងារ បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងធានាបាននូវសមធម៌ ព្រមទាំងរក្សាបាននូវស្ថិរភាព និងចីរភាពហិរញ្ញវត្ថុសាធារណៈនិងម៉ាក្រូសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ ចំណាយមូលធននឹងរក្សាត្រឹម៨,០៧% នៃផ.ស.ស.។

១៤- ដើម្បីឲ្យក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើអាចសម្រេចបានតាមគោលដៅ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តបណ្តាគោលនយោបាយ និងកម្មវិធីកែទម្រង់សំខាន់ៗដូចខាងក្រោម៖

ក. បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដ៏ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាពក្នុងបរិការណ៍នៃអត្រាអតិផរណាសមស្រប។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំ និងត្រៀមដាក់ចេញនូវបណ្តាវិធានការគោលនយោបាយថវិកាឬ/និងគោលនយោបាយរូបិយវត្ថុប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងទាន់ពេលវេលាដើម្បីទប់ទល់នឹង និងគ្រប់គ្រងលើសម្ពាធអតិផរណា និងការប្រែប្រួលនៃលំហូរមូលធន ដែលបាននិងកំពុងរាលដាល និងមានការយកចិត្តទុកដាក់ខ្ពស់នៅក្នុងតំបន់ក៏ដូចជានៅលើសកលលោក។

ខ. បន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ បន្តជំរុញ និងបង្កើនការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និងជួយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ពិសេស ជំរុញការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ព្រមទាំងជំរុញ និងលើកទឹកចិត្តដល់ផលិតកម្មនៃបណ្តាកសិផលមួយចំនួនទៀតដែលកំពុងមានសក្តានុពលខ្ពស់ដូចជា ដំឡូងមី ពោត និងកៅស៊ូ។ បន្តយកចិត្តទុកដាក់ខ្ពស់លើការបង្កើនគុណភាពសេវា វិស័យអប់រំសុខាភិបាល និងការកសាងធនធានមនុស្ស ព្រមទាំងការងារបង្កើនសុវត្ថិភាពសង្គម។ បន្តជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ប្រព័ន្ធស្រោចស្រព ព្រមទាំងបន្តបង្កបរិយាកាស និងផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជន ពិសេស ការវិនិយោគក្នុងវិស័យកសិកម្ម និងតាមរយៈយន្តការជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

គ. បន្តជំរុញការអនុវត្តកំណែទម្រង់ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបោសសម្អាតមីន ដោយផ្តោតជាសំខាន់លើការពង្រឹងប្រព័ន្ធគ្រប់គ្រង ការបែងចែកដីធ្លីប្រកបដោយសមធម៌ការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ក្នុងនោះរួមទាំងដីសម្បទានសេដ្ឋកិច្ច ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លីឲ្យសមស្របតាមច្បាប់ភូមិបាល ដើម្បីជួយគាំទ្រដល់វិស័យកសិកម្ម សំដៅលើកកម្ពស់ផលិតភាព និងពិពិធកាវូបនីយកម្មកសិកម្ម ដើម្បីឲ្យវិស័យ

នេះក្លាយទៅជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ច ហើយជាបណ្តើរៗឈានទៅកសាងវិស័យឧស្សាហកម្ម ដោយផ្តើមចេញពីឧស្សាហកម្មកែច្នៃកសិផល និងក្នុងគោលដៅធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងបម្រើឲ្យគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ឃ. បន្តពង្រឹង និងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង ទីផ្សារមូលបត្រ និងទីផ្សារភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីបង្កើនការកៀរគរធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងបង្កើនសក្តានុពលភាព និងកាលានុវត្តភាពដល់ការធ្វើហិរញ្ញប្បទាន និងការអភិវឌ្ឍវិស័យឯកជន។

ង. បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ជាពិសេស បន្តជំរុញការអនុវត្តផែនការសកម្មភាពជំហានទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដោយផ្តោតលើការរៀបចំ និងដាក់ឲ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកាថ្មីបន្ថែមទៀត អង្គភាពថវិកា ស្តង់ដារគណនេយ្យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការសាកល្បងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា។ ទន្ទឹមនឹងនេះ ការបន្តពង្រឹងភាពជឿទុកចិត្តលើថវិកានៃជំហានទី១ តាមរយៈការបន្តជំរុញការកែលម្អនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាឲ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា។ ការបន្តកសាង និងកែលម្អក្របខ័ណ្ឌគោលនយោបាយចំណូលរយៈពេលមធ្យមដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពចំណូល ពិសេស ផ្តោតការយកចិត្តទុកដាក់លើការកសាង និងពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ យន្តការគ្រប់គ្រង និងការប្រមូលពន្ធ និងអាករ ព្រមទាំងចំណូលមិនមែនសារពើពន្ធ រួមទាំងចំណូលពីធនធានធម្មជាតិផង។ លើសពីនេះ ត្រូវបន្តជំរុញពង្រឹង និងបង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដែលជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាបណ្តើរៗ និងដើម្បីឈានទៅបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម ដែលជាគោលដៅនៃជំហានទី៣ និងទី៤។

ច. បន្តការជំរុញការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពិសេស ការពង្រឹង និងពង្រីកវេទិកាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយ ព្រមទាំងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ បន្តកសាង និងកែលម្អច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសហការរៀបចំពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ខ្លួន ដើម្បីកំណត់មុខងារ និងធនធានសម្រាប់ផ្ទេរឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងស្មារតីទទួលខុសត្រូវពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព។

ឆ. បន្តជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។ ក្នុងន័យនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវរៀបចំគោលនយោបាយរយៈពេលមធ្យម និងវែងសម្រាប់ការកែលម្អការគ្រប់គ្រងធនធានមនុស្សប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវបង្កើតយន្តការ និងបង្កើន

ប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ ការពង្រឹងការផ្តល់ទិដ្ឋាការឲ្យជ្រើសមន្ត្រីថ្មីបន្ថែម ដោយផ្អែកលើការវិភាគលើតម្រូវការជាក់ស្តែង និងលទ្ធភាពថវិកាជាតិ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការចូលនិវត្តន៍។ ទន្ទឹមនឹងនេះ ត្រូវពិនិត្យពិចារណាឡើងវិញលើរាល់គោលនយោបាយ និងគោលការណ៍ដំឡើង និងផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងការដំឡើងបៀវត្សមូលដ្ឋានប្រចាំឆ្នាំ ការដំឡើងកាំប្រាក់ ការអនុវត្តប្រាក់បំណាច់មុខងារ ការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចជា ប្រាក់ម៉ោង ប្រាក់យាម ប្រាក់បេសកកម្ម និងចំណាយប្រតិបត្តិការអាទិភាពជាដើម ដើម្បីធានាសមធម៌ តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព។

ជ. បន្តជំរុញការអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេស ការពង្រឹងសមត្ថភាពដឹកនាំ វិជ្ជាជីវៈជំនាញ សហប្រតិបត្តិការ និងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ និងការកាត់រំសាយកងទ័ព ដើម្បីធានាការប្រើប្រាស់ និងគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់។

ឈ. បន្តជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ពិសេស ការបន្តរៀបចំ និងពង្រឹងសមត្ថភាព អង្គភាពប្រឆាំងអំពើពុករលួយដើម្បីអាចដំណើរការ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងការអប់រំ ទប់ស្កាត់ និងបោសសម្អាតអំពើពុករលួយ។

## III. ការគណនា និងទិសដៅថវិកាឆ្នាំ២០១៤

### ក- <u>គម្រោងចំណាយថវិកា</u>

១៥- ដើម្បីធានាបាននូវការអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈដែលបានកំណត់ខាងលើ ពិសេស ដើម្បីអនុវត្តតាមគោលការណ៍ និងវិធានការដូចបានគូសបញ្ជាក់ខាងលើ ការគ្រោងចំណាយថវិកាឆ្នាំ២០១៤ ត្រូវផ្អែកលើមូលដ្ឋាន *បង្កើនប្រសិទ្ធភាពចំណាយ* ដូចខាងក្រោម ៖

• បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយ អគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ជៀសវាងបេសកកម្មបរទេស ឬការរៀបចំប្រជុំនៅក្នុងប្រទេស ដែលពុំសូវចាំបាច់ បន្ថយការទិញសម្ភារៈប្រណិត ការទិញសម្ភារៈថ្មី និងការបោះពុម្ពដែលមិនសូវចាំបាច់ ព្រមទាំងផ្អាកការសាងសង់អគារថ្មី ឬការជួសជុលដែលមិនចាំបាច់ ដើម្បីរក្សាចំណាយសរុបថវិការដ្ឋឲ្យស្ថិតនៅត្រឹមកម្រិត២០,១៣% នៃផ.ស.ស. គឺកើនឡើង០,០៤% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលក្នុងនោះចំណាយចរន្តថវិការដ្ឋនឹងត្រូវរក្សាឲ្យនៅត្រឹម១២,០៦% នៃផ.ស.ស. (ថយចុះ០,០១% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣) និងចំណាយមូលធននឹងត្រូវរក្សាឲ្យនៅត្រឹម៨,០៧% នៃផ.ស.ស. (កើនឡើង០,០៥% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣) ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់២,៩៩% នៃផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់-៤,៩០% នៃផ.ស.ស.។ ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងកម្រិត២,៥៤% នៃផ.ស.ស. គឺកើនឡើង០,០២% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងចំណាយសម្រាប់រំលស់

បំណុលត្រូវកំណត់ត្រឹម០,៤៨% នៃផ.ស.ស. គឺកើន០,០៣% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវបានគ្រោងក្នុងកម្រិត៥,០៤% នៃផ.ស.ស. គឺកើនប្រមាណ១០% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

• ត្រូវវិភាជន៍ចំណាយចរន្តថវិកាថ្នាក់ជាតិទៅតាមវិស័យនីមួយៗ ដូចតទៅ: វិស័យសង្គមកិច្ចស្មើនឹង៤,៤៧% នៃផ.ស.ស. គឺកើនឡើង០,០៦% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ វិស័យសេដ្ឋកិច្ច១,០៤% នៃផ.ស.ស. គឺកើនឡើង០,០៩% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ វិស័យរដ្ឋបាលទូទៅ១,៦០% នៃផ.ស.ស. គឺថយចុះ០,១៦% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ វិស័យការពារជាតិនិងសន្តិសុខ២,៦០% នៃផ.ស.ស. គឺកើនឡើង០,០៣% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

• ថវិការាជធានី ខេត្ត ត្រូវកំណត់ត្រឹម០,៩៩% នៃផ.ស.ស. ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ០,៧៩% នៃផ.ស.ស. មានកំណើន០,០៩% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី ខេត្ត និងក្រុង ស្រុកស្មើនឹង០,២០% នៃផ.ស.ស. ដែលក្នុងនោះ ថវិកាដែលត្រូវផ្ទេរសម្រាប់មូលនិធិក្រុង ស្រុក សម្រាប់ឆ្នាំ២០១៤ ត្រូវបានកំណត់ស្មើនឹង០,៨% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំដោយឡែកសម្រាប់ការរៀបចំថវិកាថ្នាក់ក្រោមជាតិ ដោយឈរលើមូលដ្ឋាននៃសារាចរណែនាំនេះ ជាពិសេស ការកំណត់កញ្ចប់ និងការវិភាជន៍ថវិកាទៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគោរពទៅតាមគោលការណ៍ និងវិធានតាមជំពូកដូចបានកំណត់នៅក្នុងសារាចរណែនាំនេះ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល និងប្រសិទ្ធភាពចំណាយ ដើម្បីកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

១៦- ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០១៤ ត្រូវបន្តបម្រើឲ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងការលើកស្ទួយជីវភាពប្រជាជននៅទីជនបទសំដៅសម្រេចឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ថវិកាឆ្នាំ២០១៤ ត្រូវផ្តល់ការវិភាជន៍ជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗ ដូចខាងក្រោម:

• បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាពសង្គម កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ ព្រមទាំងការពង្រីកការកែលម្អ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន មន្ទីរពេទ្យ ។ល។

• បន្តផ្តល់មូលនិធិថវិកាឃុំ សង្កាត់ឆ្នាំ២០១៤ ក្នុងកម្រិត២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ហើយត្រូវបានគណនាស្មើនឹង០,៣៥% នៃផ.ស.ស.។

• ចំពោះថវិកាថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងរាល់នីតិវិធីដែលមានជាធរមានស្របតាមមាត្រា៨៧ នៃអនុក្រឹត្យស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ទាំងថវិកាផ្ទាល់ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិ ក្នុងពេលដែលការរៀបចំក្របខ័ណ្ឌគតិយុត្តិសម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលកំណត់ និងផ្ទេរមុខងារដើម្បីឈានទៅបង្កើតថវិការាជធានី ខេត្ត និងក្រុង ស្រុក នៅពុំទាន់ចប់សព្វគ្រប់នៅឡើយ។

• បន្តផ្តល់អាទិភាពវិភាជន៍ថវិកាដល់ថវិកាកម្មវិធី និងផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានបញ្ជាក់ពីទិសដៅគោលនយោបាយ គោលបំណង កម្មវិធី និង/ឬយុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និងសូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ក្នុងគោលដៅបន្តពង្រឹង និងការកែលម្អការរៀបចំ និងការអនុវត្តថវិកាកម្មវិធី។

ខ- <u>គម្រោងចំណូលថវិកា</u>

១៧- ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគម្រោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និងការអនុវត្តឲ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចឲ្យបាននូវកម្រិតចំណូលក្នុងស្រុកថវិការដ្ឋប្រមាណ១៥,២៣% នៃផ.ស.ស. គឺកើនឡើង០,៥៤% នៃផ.ស.ស. និងមានកំណើនប្រមាណ១៤,២% ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសម្រេចឲ្យបាន១២,៩៦% នៃផ.ស.ស. គឺមានកំណើន០,៥៣% នៃផ.ស.ស. ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣ និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១០% នៃផ.ស.ស. គឺថយចុះ០,០៣% នៃផ.ស.ស. ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ ចំណូលមូលធនក្នុងស្រុកត្រូវសម្រេចឲ្យបាន០,១៧% នៃផ.ស.ស. គឺកើនឡើង០,០៤% នៃផ.ស.ស. ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣។

១៨- ដើម្បីសម្រេចបានតាមគោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តជំរុញឲ្យកាន់តែសកម្មថែមទៀតក្នុងការអនុវត្តសកម្មភាពការងារ និងបណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

ទី១-<u>ផ្នែកចំណូលពន្ធដារ</u>

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តឲ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈ៖

• បន្តពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ។
• ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ។

• ពង្រឹងការគ្រប់គ្រងប្រមូលពន្ធនៅតាមសាខាពន្ធដារខេត្ត ខណ្ឌ ដែលមានទាំងរបបឆ្លើយប្រកាស និងរបបម៉ៅការ ជាពិសេស ពង្រឹងការកំណត់ផលរបររបស់អ្នកជាប់ពន្ធឲ្យស្រប តាមនឹងការជាក់ស្តែង ក្នុងទិសដៅបង្កើនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស បន្ថយបរិមាណអ្នកជាប់ពន្ធតាមរបបម៉ៅការ និងពិនិត្យសហគ្រាសមួយចំនួនដែលមិនទាន់មកបង់ពន្ធឲ្យមកបង់ពន្ធ។

• បន្តពង្រឹងការអនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយ និងឲ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ(ពន្ធដារ) និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ។

• បន្តរៀបចំនិងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨។

- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រតាមប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និងឧស្ម័ន ដើម្បីធានាឲ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និងឧស្ម័ន។

- បន្តធ្វើការសិក្សាអំពីវិចារណកម្ម និងលទ្ធភាពវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងបណ្តាច្បាប់ពាក់ព័ន្ធក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ។

- ពង្រឹងការធ្វើសវនកម្ម ជាពិសេស បន្តពង្រឹងការធ្វើសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ និងការធ្វើសវនកម្មលើសហគ្រាសធំៗសំខាន់ៗឲ្យមានតម្លាភាពក្នុងការប្រកាសបង់ពន្ធឲ្យបានត្រឹមត្រូវ។

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា ព្រមទាំងធនាគារពាណិជ្ជនានា អគ្គិសនីកម្ពុជា កាំកុងត្រូល ដើម្បីប្រមូលព័ត៌មាន និងសហការជាមួយអគ្គស្នងការនគរបាលជាតិ ក្នុងការចាប់បង្ខំឲ្យអ្នកជាប់ពន្ធគោរពប្រតិបត្តិច្បាប់ ព្រមទាំងអនុវត្តវិធានការតឹងទារ ដោយបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល មិនពិនិត្យសំណើសុំនាំចូលតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាត់ទុកប្រាក់ពន្ធនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងការផ្សព្វផ្សាយឈ្មោះក្នុងទំព័រសារព័ត៌មានមុននឹងអនុវត្តវិធានការប្តឹងទៅតុលាការដែលជាជម្រើសចុងក្រោយ។

- ពង្រឹងសេវាអ្នកជាប់ពន្ធ ដោយធ្វើការឆ្លើយតបជាលាយល័ក្ខណ៍អក្សរ និងតាមទូរស័ព្ទនូវចម្ងល់ ឬសំណួររបស់អ្នកជាប់ពន្ធ និងបោះពុម្ពជាកូនសៀវភៅ ឬប័ណ្ណពន្យល់ណែនាំដល់អ្នកជាប់ពន្ធ ដើម្បីឲ្យអ្នកជាប់ពន្ធមានការយល់ដឹងពីច្បាប់ស្តីពីសារពើពន្ធ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលពន្ធដារឲ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឲ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។

ទី២-<u>ផ្នែកចំណូលពន្ធគយនិងរដ្ឋាករ</u>

- បន្តរៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨។

- បន្តជំរុញការរៀបចំតាមការចាំបាច់នៃការងារនូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់គយ ពិសេស សម្រាប់បន្តកែលម្អបរិស្ថានធុរកិច្ច និងវិនិយោគ និងសម្រាប់តែបន្ថឹងវិធានការបំបាត់អំពើរត់ពន្ធគយ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ-ចូល ដោយតម្រូវឲ្យមានការរៀបចំជាក្រុមហ៊ុននាំចេញ-ចូល និងក្រុមហ៊ុនដើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និងភាពងាយស្រួលក្នុងការត្រួតពិនិត្យ និងក្នុងការយកពន្ធ និងអាករផ្សេងៗ។

- បន្តរៀបចំកែលម្អនិងដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

- បន្តជំរុញការអនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមានៈ

• បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឲ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀតក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសលើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេទយិតភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារ អេឡិចត្រូនិច និងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី។

• បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និងកាតព្វកិច្ចពន្ធដារ។

• បន្តរិះរក និងដាក់ឲ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយនិងរដ្ឋាករមានជាអាទិ៍ៈ បន្តការបណ្តុះបណ្តាល និងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និងសីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលគយឲ្យបានរឹងមាំ។

- បន្តពង្រឹង និងពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និងយន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលើកកម្ពស់គុណភាពសេវាកម្មជូនដល់អតិថិជន។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ទី៣-ផ្នែកចំណូលមិនមែនសារពើពន្ធ

- បន្តរៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨។

- បន្តពង្រឹង និងជំរុញឲ្យបានជោគជ័យនូវវិធានការកែទម្រង់ការគ្រប់គ្រងកំរៃសេវារដ្ឋបាលរបស់រដ្ឋដែលទើបនឹងត្រូវបានដាក់ចេញក្នុងពេលថ្មីៗកន្លងមក។

- បន្តជំរុញការដាក់ឲ្យអនុវត្តបង្កាន់ដៃជាតិសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទនៅតាមគ្រប់ក្រសួង ស្ថាប័ន ក្នុងគោលដៅបង្កើនការគ្រប់គ្រង និងការប្រមូលចំណូល។

- បន្តជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០២ បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

- បន្តជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ពិសេស បន្តពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីធានាឲ្យមានការបង់ចំណូលទាំងនេះចូលថវិការដ្ឋឲ្យបានទៀងទាត់ ទាន់ពេលវេលា និងដោយគ្មានការកាត់ទុកសម្រាប់ចំណាយដោយប្រការណាមួយឡើយ។

- បន្តស្រាវជ្រាវ និងកំណត់ឲ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយ បន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះតាមគ្រប់មុខសញ្ញាទាំងអស់។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូល។

- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទចូលថវិកាជាតិ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឲ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិនៃកម្ពុជា ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ។

គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

១៩- ពិតណាស់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាននិងកំពុងធ្វើឲ្យការគ្រប់គ្រងចំណូល និងចំណាយកាន់តែល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងត្រូវបានឆ្លុះបញ្ចាំងដោយកំណើនឡើងនៃភាពជឿទុកចិត្តលើថវិកា ដែលធ្វើឲ្យរាជរដ្ឋាភិបាលដោះស្រាយបំណុលចាស់បានទាំងស្រុង និងបញ្ឈប់បាននូវប្រពៃណីខ្វះសាច់ប្រាក់ទូទាត់ចំណាយ ហើយថែមទាំងដោះស្រាយបាននូវវិបត្តិសេដ្ឋកិច្ច និងវិបត្តិព្រំដែនក្នុងពេលថ្មីៗកន្លងទៅទៀតផង។ ទន្ទឹមនឹងបញ្ហាប្រឈមចំពោះមុខដែលត្រូវបន្តជំរុញការបង្កើនចំណូលពន្ធដាក្នុងស្រុក ដើម្បីបំពេញនិន្នាការថយចុះនៃចំណូលពន្ធនាំចូល និងហានិភ័យនៃកត្តាខាងក្រៅដែលអាចជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច និងចំណូលជាយថាហេតុ រាជរដ្ឋាភិបាលត្រូវបន្តជំរុញការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធក្នុងការគ្រោងការអនុវត្ត និងការគ្រប់គ្រងចំណូល និងចំណាយ ដើម្បីអាចដោះស្រាយប្រកបដោយប្រសិទ្ធភាពទៅនឹងតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់។ ប្រការនេះ ទាមទារឲ្យរាជរដ្ឋាភិបាល ពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការត្រូវតែបន្តជំរុញបន្ថែមទៀតនូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២នេះ ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តលើថវិកាឲ្យកាន់តែរឹងមាំ បន្តបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឲ្យកាន់តែល្អប្រសើរ និងជាបណ្តើរៗបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈការផ្តោតលើការងារសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

ទី១- *ត្រូវបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឲ្យបានសមស្រប ព្រោះ វាជាមូលដ្ឋានដ៏សំខាន់របស់ក្រសួង ស្ថាប័ន ក្នុងការគូសបញ្ជាក់អំពីគោលបំណងគោលនយោបាយរបស់ខ្លួន ដើម្បីការពារ និងអះអាងលើតម្រូវការចំណាយរបស់ខ្លួន និងដើម្បីជានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។* ត្រូវពង្រឹងការរៀបចំថវិកាឲ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹត ដើម្បីកាត់បន្ថយជាអតិបរមានូវចំណាយមិនបានគ្រោងទុក និងសំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និងចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយភាពជឿទុកចិត្តបាន គណនេយ្យភាព និងប្រសិទ្ធភាព។

ទី២- ត្រូវបន្តជំរុញការរៀបចំផែនការលទ្ធកម្ម និងកម្មវិធីចំណូល-ចំណាយឲ្យបានទាន់ពេលវេលា សុក្រឹត និងអនុវត្តឲ្យបានម៉ឺងម៉ាត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ជានាបន្តពង្រឹងភាពជឿទុកចិត្តលើថវិកា បង្កើនគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា។ ទន្ទឹមនឹងនេះ ត្រូវបន្តបង្កើនការគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងវិន័យថវិកាទាំង១០។

ទី៣- ត្រូវបន្តពង្រឹងការគ្រប់គ្រងបំណុល ពិសេស ការអនុវត្តយុទ្ធសាស្ត្រ និងយន្តការគ្រប់គ្រងបំណុលរបស់រាជរដ្ឋាភិបាល ការកសាងទិន្នន័យ ការរៀបចំកម្មវិធីសងបំណុលឲ្យបានច្បាស់លាស់និងដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងថវិកាប្រចាំឆ្នាំ និងការបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការខ្ចីតែឥណទានសម្បទាន និងដែលបម្រើឲ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

ទី៤- ត្រូវបន្តត្រៀមលក្ខណៈ និងគ្រប់គ្រងឲ្យបានល្អនូវបណ្តាបញ្ហាប្រឈមថ្មី ឬជាយថាហេតុ ដូចជា សម្ពាធអតិផរណា ចំណាយសម្រាប់ដោះស្រាយគ្រោះធម្មជាតិ តម្រូវការចំណាយសម្រាប់ការការពារអធិបតេយ្យ និងបូរណភាពទឹកដី ព្រមទាំងកាតព្វកិច្ចអន្តរជាតិ និងកិច្ចប្រជុំផ្សេងៗដែលចេះតែកើនឡើងជាលំដាប់។

## IV- នីតិវិធី និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៤

### ក- ការគ្រោងចំណូលថវិកាឆ្នាំ២០១៤

២០- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងបណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្តត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ។
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ។
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ។ ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ។
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបានដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធនិងការប្រមូលបំណុលពន្ធដែលត្រូវទារ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឲ្យមានផលទុនដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

### ខ-ការគ្រោងចំណាយថវិកាឆ្នាំ២០១៤

១- *ការរៀបចំគម្រោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគណនាតម្រូវការថវិកាដោយលម្អិតទៅតាមជំពូក គណនី និងអនុគណនី និងដោយផ្អែកលើតម្រូវការចំណាយជាក់ស្តែង និងដោយផ្ទាល់សម្រាប់អនុវត្តសកម្មភាពការងារ របស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ឬផ្នែកនីមួយៗចំណុះឲ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត (តាមគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ) ដើម្បីបម្រើឲ្យកម្មវិធី/យុទ្ធសាស្ត្រអាទិភាពចាំបាច់ របស់ក្រសួង ស្ថាប័នក្នុងការសម្រេចនូវគោលបំណងគោលនយោបាយរបស់ខ្លួនដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។* រីឯការគណនាឥណទានចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជាតារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតម្លៃសម្ភារៈនៃការផ្គត់ផ្គង់ និងត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬសេចក្តីណែនាំ

ដូចជាចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយដំណើរការសាលាសម្រាប់សិស្ស ឬនិស្សិតម្នាក់ ឬត្រូវផ្អែកទៅតាមតួលេខ ស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសម្រាប់ការគ្រប់គ្រងកន្លងមក។ ជាពិសេស តម្រូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និងមានឯកសារគាំទ្រភ្ជាប់មកជាមួយដើម្បីពន្យល់ទៅតាមជំពូក គណនី និងអនុគណនីនីមួយៗ។

គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ២០១៤

២២- រាជរដ្ឋាភិបាលបានធ្វើការកំណត់កញ្ចប់ថវិកា ដោយកំណត់ជាគោលការណ៍ចំណាយទៅតាមប្រភេទ និងជំពូក ដោយផ្អែកលើស្ថានភាព និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សម្រាប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ធ្វើជាមូលដ្ឋានក្នុងការរៀបចំគម្រោងចំណាយលម្អិតទៅតាមគណនី និងអនុគណនី និងទៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ឬផ្នែកនីមួយៗចំណុះឲ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្នុងការអនុវត្តសកម្មភាពការងារជាក់ស្តែង និងចាំបាច់របស់ខ្លួន ដើម្បីបម្រើឲ្យកម្មវិធី/យុទ្ធសាស្ត្រអាទិភាព និងដើម្បីសម្រេចបានតាមគោលដៅនៃគោលបំណងគោលនយោបាយរបស់ខ្លួន ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ *ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវបានអនុញ្ញាតឲ្យធ្វើចាប់ពីត្រីមាសទី៣ គឺបន្ទាប់ពីការអនុវត្តបាន២ត្រីមាស។*

២៣- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងបណ្តាវិធានការដូចខាងក្រោម៖

ក- ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤) ត្រូវគ្រោងទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៣។ រាជរដ្ឋាភិបាលបានគ្រោងកញ្ចប់ថវិការួមមួយសម្រាប់ដំឡើងបៀវត្សឆ្នាំ២០១៤ ប៉ុន្តែដោយសាររាជរដ្ឋាភិបាលកំពុងរៀបចំក្របខ័ណ្ឌ និងយុទ្ធសាស្ត្រសម្រាប់ការដំឡើងបៀវត្សនេះប្រកបដោយសមធម៌ សង្គតិភាព និងប្រសិទ្ធភាព ជាពិសេសដើម្បីធានាឲ្យមានគំលាតសមស្របរវាងអ្នកមានបៀវត្សខ្ពស់ និងទាប ព្រមទាំងធានាស្ថិរភាពនិងចីរភាពថវិកា ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈនិងម៉ាក្រូសេដ្ឋកិច្ច គ្រប់ក្រសួងស្ថាប័ន ត្រូវគ្រោងទៅតាមមូលដ្ឋាននៃក្របខ័ណ្ឌបៀវត្សបច្ចុប្បន្នសិន នៅពេលដែលក្របខ័ណ្ឌនិងយុទ្ធសាស្ត្រនៃការអនុវត្តប្រព័ន្ធបៀវត្សថ្មីត្រូវបានអនុម័ត រាជរដ្ឋាភិបាលនឹងបំពេញបន្ថែមនូវថវិកាសម្រាប់ការអនុវត្តតាមក្របខ័ណ្ឌថ្មីនៃប្រព័ន្ធបៀវត្ស ដល់គ្រប់ក្រសួង ស្ថាប័នជាក្រោយ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន និងមិនត្រូវគ្រោងទេ។ ចំពោះការឡើងឋានៈ និងកាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មិនត្រូវគិតអតិផរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។ ចំពោះបុគ្គលិកអណ្តែត និងភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឲ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ជ្រើសរើស និងប្រើប្រាស់ ។

ខ- ចំណាយសម្រាប់ការទិញ និងសេវា (ជំពូក៦០ ជំពូក៦១ និងជំពូក៦២) ត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃបំផុត ពិសេសលើមុខសញ្ញាទិញឧបករណ៍សម្ភារៈបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត ការជួសជុលធំ សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវ និងបេសកកម្មក្រៅប្រទេស ព្រមទាំង សោហ៊ុយចំណាយជាអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី និងទឹកជាដើម។ ការគ្រោងចំណាយឆ្នាំ២០១៤ សម្រាប់ជំពូកការទិញ និងសេវានេះ ត្រូវកំណត់ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ដូច្នេះ មានន័យថាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវផ្អែកលើកញ្ចប់ឥណទានថវិកាឆ្នាំ២០១៣ នៃជំពូកចំណាយសម្រាប់ការទិញ និងសេវា ហើយកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ/និងមុខចំណាយដែលបម្រើឲ្យសកម្មភាពដែលត្រូវបានបញ្ចប់ រួចធ្វើការវិភាជន៍ឡើងវិញសម្រាប់សកម្មភាពថ្មី ឬ/និងដើម្បីបង្កើនប្រសិទ្ធភាពចំណាយ។

គ- ចំណាយសម្រាប់ការឧបត្ថម្ភកធន និងជំនួយសង្គម(ជំពូក៦៥) ត្រូវគ្រោងទៅតាមតម្រូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ចំពោះ ចំណាយដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវអនុវត្តដោយផ្ទាល់ ត្រូវគ្រោងទៅតាមគោលការណ៍ ឬ/និងកិច្ចសន្យា ដែលជាកាតព្វកិច្ចរបស់រដ្ឋ និងនៅជាធរមាន។ ការគ្រោងចំណាយឆ្នាំ២០១៤ សម្រាប់ជំពូកចំណាយឧបត្ថម្ភកធន និងជំនួយសង្គមនេះ ត្រូវកំណត់ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ទោះជាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មានគោលនយោបាយ គោលការណ៍ ឬ/និងកិច្ចសន្យាថ្មីក៏ដោយ។ ដូច្នេះ មានន័យថាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវផ្អែកលើកញ្ចប់ឥណទានថវិកាឆ្នាំ២០១៣ នៃជំពូកចំណាយសម្រាប់ការឧបត្ថម្ភកធន និងជំនួយសង្គម ហើយកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ/និងមុខចំណាយដែលបម្រើឲ្យសកម្មភាពដែលត្រូវបានបញ្ចប់ រួចធ្វើការវិភាជន៍ឡើងវិញសម្រាប់សកម្មភាពការងារដែលត្រូវបន្ត និងសម្រាប់គោលនយោបាយ ឬ/និងសកម្មភាពថ្មី ប្រសិនបើមាន ឬ/និងដើម្បីបង្កើនប្រសិទ្ធភាពចំណាយ។ ក្នុងករណីមានគោលនយោបាយ ឬ/និងសកម្មភាពថ្មីដែលការវិភាជន៍ឡើងវិញពីកញ្ចប់ឥណទានថវិកាឆ្នាំ២០១៣ មិនអាចគ្រប់គ្រាន់សម្រាប់បម្រើឲ្យគោលនយោបាយ ឬ/និងសកម្មភាពថ្មីនោះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវលើកគម្រោងចំណាយនោះដោយឡែក ពិសេស សម្រាប់អាជ្ញាធរ គណៈកម្មាធិការ ឧត្តមក្រុមប្រឹក្សា ក្រុមប្រឹក្សា និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងអង្គភាពដែលចំណុះឲ្យក្រសួង ស្ថាប័ន។ ដោយឡែកចំពោះចំណាយដែលត្រូវអនុវត្តដោយអង្គភាពស្វយ័ត ឬអង្គភាពដែលមានថវិកាដោយឡែក ត្រូវគ្រោងដោយផ្អែកលើគោលការណ៍តាមជំពូកដែលបានកំណត់នៅក្នុងចំណុចក និងខ ខាងលើ។ ចំពោះក្រសួង ស្ថាប័ន ដែលត្រូវបន្ត ឬចាប់ផ្តើមអនុវត្តសាកល្បងថវិកាកម្មវិធី ត្រូវញែកគម្រោងចំណាយជាពីរផ្នែក សម្រាប់ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី ទៅតាមគ្រប់ជំពូក គណនី និងអនុគណនី

- នីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំងនេះមកការពារគម្រោងថវិកាកម្មវិធីដោយឡែក។

ឃ- ការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិកត្រូវផ្អែកលើមូលដ្ឋានពីរគឺៈ ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងប្រសិទ្ធភាពនៃចំណាយ ជាពិសេសដើម្បីមានមូលដ្ឋានច្បាស់លាស់សម្រាប់ធ្វើជាអំណះអំណាងនៃតម្រូវការថវិកា ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវធ្វើការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក(ជំពូក៦០ ជំពូក៦១ ជំពូក៦២ និងជំពូក៦៥) ដោយផ្អែកលើមូលដ្ឋានពីរដូចខាងក្រោមៈ

- *កំណត់ចំណាយជាប្រចាំហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះឲ្យបានច្បាស់លាស់។* ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយសម្ភារៈផ្គត់ផ្គង់ថែទាំជាប្រចាំ(ដូចជាសម្ភារៈផ្គត់ផ្គង់ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារៈផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជាសម្ភារៈការិយាល័យ ការបោះពុម្ព និងទិញឯកសារ សម្ភារៈបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើ អគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះគួរកំណត់ឲ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឲ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជន៍ទៅតាមនាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។

- *កំណត់ចំណាយមិនជាប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឲ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយបំពាក់ឧបករណ៍សម្ភារៈការិយាល័យ ឧបករណ៍សម្ភារៈដឹកជញ្ជូន សម្ភារៈបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារៈប្រើប្រាស់ផ្សេងៗដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះគួរកំណត់ឲ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់កាចំណាយប្រភេទនេះសម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

ង- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកាឆ្នាំ២០១៤ ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាមូលដ្ឋានសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិកាដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ការប្រជុំការពារថវិកាទេ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះឲ្យបានទាន់ពេលវេលាដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅ

តែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃថវិកាឆ្នាំ២០១៣ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើសម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការប្រជុំការពារថវិកា និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ឲ្យបានទាន់ពេលវេលា។

**ឃ-ការរៀបចំ និងការវិភាគសំណើនានា**

២៤- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ(n-1) ឆ្នាំ២០១៣ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១២ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ២០១៤ ឆ្នាំ(n) ដើម្បីធានាឲ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និងការណែនាំទាំងឡាយខាងលើនេះសម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា៖
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឲ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្តមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។
- ផលប៉ះពាល់ដោយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និងចំណាយរដ្ឋបាល។ល។

២៥- គម្រោងថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបានលុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ។

២៦- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួល អាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬមានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ។

២៧- បច្ចេកទេសវិភាគដទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និងអត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួនសម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ត្រូវតែបម្រើទៅលើ៖

- ទិសដៅ និងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

- កម្មវិធី និងយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសម្រេចបាននូវគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន។
- ផែនការសកម្មភាព និងពេលវេលាមធ្យោបាយដំណើរការ ដើម្បីអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព។
- ការគ្រប់គ្រង ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសម្រាប់សម្រេចបានគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន។

២៨- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឲ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ជាមួយក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឲ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៣ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឲ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៣ ដើម្បីស្ថាប័ននីតិបញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឲ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣។

## V- **សេចក្តីសន្និដ្ឋាន**

២៩- ខ្លឹមសារនៃសារាចរណែនាំនេះ បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគោលការណ៍ និងនីតិវិធីក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួនឲ្យឆ្លើយតបទៅនឹងកម្មវិធី យុទ្ធសាស្ត្រអាទិភាព ព្រមទាំងទិសដៅ និងគោលបំណងនៃគោលនយោបាយ តាមវិស័យនិងតាមផ្នែករៀងៗខ្លួន សំដៅបម្រើឲ្យបានសម្រេចនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ប្រកបដោយជោគជ័យ គឺការរក្សាកំណើនប្រកបដោយចីរភាពក្នុងរង្វង់ប្រមាណ៧% និងការកាត់បន្ថយភាពក្រីក្រឲ្យបានលើស១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សាឲ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុតក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ភាពសុខដុមរមនាសង្គម និងសុខុមាលភាពរបស់ប្រជាជន។ ដូច្នេះ ដើម្បីឲ្យធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់នោះ ទាមទារឲ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់មានទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ខ្លួន យ៉ាងច្បាស់លាស់ដែលផ្សារភ្ជាប់ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល មានកម្មវិធី និងយុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវក្នុងការអនុវត្តឆ្ពោះទៅសម្រេចឲ្យបាននូវគោលបំណង និងទិសដៅនៃ

គោលនយោបាយរបស់ខ្លួន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ជាពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៣០- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ការចរចាចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម0,1 លានរៀល។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ